ខាងក្រោយព័ត៌មាន-បញ្ហាប្រឈមមុខនិងសេចក្តីត្រូវការពីអ្នកយកព័ត៌មានស្ត្រីនៅអាស៊ីនិងប៉ាស៊ីហ្វិក

អនុសាសន៍ការសិក្សាស្រាវជ្រាវ

## **សមភាពជេនឌ័រក្នុងអង្គការសារព័ត៌មាន។**

១ សារព័ត៌មានអាចជាគំរូទៅលើសមភាពជេនឌ័រ។ ករណីនេះអង្គការសារព័ត៌មាននៅក្នុងអាស៊ីនិងប៉ាស៊ីហ្វិកគួរណាស់អនុវត្តន៍នយោបាយជេនឌ័រនិងឱកាសស្មើគ្នានិងដើម្បីជាការធានាថានយោបាយនេះត្រូវមានការសន្ទនានិងបុគ្គិកទាំងអស់និងយកទៅអនុវត្តន៍ជាប្រធានបទសាមញ្ញទូទៅ។ នយោបាយណាក៏ដោយគួរតែបញ្ជូលការកំណត់និយមន័យដើម្បីចំរុះភាពនិងបញ្ជូលក្រុមដែលត្រូវស្ថិតនៅឯកោនិងធ្វើការទាមទារដើម្បីឱ្យមានការយល់ដឹងអំពីសមភាពជេនឌ័រ សិក្ខាសាលាសំរាប់អ្នកធ្វើសំរេចទាំងថ្នាក់មធ្យមនិងកំរិតបណ្ណាធិការថ្នាក់មធ្យមនិងអារុំសោជើងចាស់រួមទាំងអ្នកគ្រប់គ្រងថ្នាក់លើទៀត។ គណៈកម្មការផ្ទៃក្នុងទទួលបន្ទុកកិច្ចការជេនឌ័រគួរណាស់ត្រូវតែមានការណែនាំឱ្យមានក្នុងក្រុមហ៊ុនសារព័ត៌មានដែលមានបុគ្គលិកបំរើការងារច្រើនជាង ៥០០ នាក់ដើម្បីដោះស្រាយការតវ៉ាបញ្ហានិងដើម្បីផ្តល់ការយល់ដឹងដើម្បីកសាងឱ្យមានបរិយាកាសការងារដែលមានសមភាពរវាងស្ត្រីនិងបុរស។

២ សកម្មភាពជាវិជ្ជមានត្រូវតែឱ្យកើតមានឡើងដើម្បីយកជ័យជំនះទៅលើបញ្ហាការរើសអើងនៅទីកន្លែងធ្វើការងារទាំងចំពោះមុខឬប្រយោល។ សារព័ត៌មានគួរផ្តួចផ្តើមគំនិតបង្កើតឱ្យមានដោយខ្លួនឯងក៏ប៉ុន្តែឱ្យមានឯករាជទៅលើការវាយតំលៃជេនឌ័រក្នុងអង្គការរបស់ខ្លួនហើយនៅក្នុងនោះរួមមានការជួលអ្នកសិក្សាវាយតំលៃដើម្បីសិក្សាពិនិត្យទៅលើប្រធានបទគំលាតប្រាក់ខែនិងភាពខុសគ្នានិងលក្ខ័ណការចូលធ្វើការនិងកិច្ចសន្យាជំនួល។ ហើយអ្នកសិក្សាវាយតំលៃបែបនេះត្រូវតែធ្វើការធានារក្សាការសម្ងាត់និងមានតម្លាភាពនិងដោយមានការចូលរួមនិងអនុវត្តន៍ដោយមានយុទ្ធសាស្ត្រសមរម្យត្រឹមត្រូវ។

៣  ក្រុមហ៊ុនសារព័ត៌មានគួរតែធ្វើការពិចារណាឱ្យបានយ៉ាងម៉ឺងម៉ាត់ហ្មត់ចត់ទៅលើការអនុវត្តន៍យុទ្ធសាស្ត្រការទទួលយកបុគ្គលិកចូលបំរើការងារឱ្យមានភាពជាវិជ្ជមានដោយសំដៅទៅលើស្ត្រីភេទក្នុងវិស័យសារព័ត៌មានដែលជាតំបន់ដែលអ្នកទាំងអស់គ្នាបានយល់ឃើញយ៉ាងជាក់ច្បាស់ថាស្ថិតនៅក្រោមឥទ្ធិពលពីបុរសភេទ។

៤  ក្រុមហ៊ុនសារព័ត៌មានត្រូវតែយល់ឱ្យបានយ៉ាងច្បាស់ទៅលើផលប៉ះពាល់និងប្រយោជន៍នៃបរិយាកាសការងារដែលមានលក្ខណៈជាមិត្តនិងគ្រួសារ ហើយជាធម្មតាទូទៅសុខមាលភាពនិងការពេញចិត្តចំពោះបុគ្គិកទាំងអស់នៅក្នុងកន្លែងធ្វើការហ្នឹង។ ក្រុមហ៊ុនសារព័ត៌មានគួរធ្វើការដោយសំដៅឆ្ពោះទៅលើគោលដៅយុទ្ធសាស្ត្រការកសាងឱ្យមានបរិយាកាកបែបមានលក្ខណៈជាមិត្តជាគ្រួសារក្នុងនោះរួមមានផងដែរគឺការរៀបឱ្យមានមធ្យោបាយការធ្វើដំណើរក្រោយពីការធ្វើការនៅពេលយប់ ការរៀបចំឱ្យមានកន្លែងសំរាប់ចិញ្ចឹមកុមារទារកនៅពេលធ្វើការងារ ការអនុវត្តន៍គោលការណ៍ឈប់សំរាកចំពោះស្ត្រីដែលមានផ្ទៃពោះ

និងការផ្ដល់ការឈប់សំរាកក្រោយពេលបានឆ្លងទន្លេនិងការរៀបចំឱ្យមានលក្ខណៈការធ្វើការងារដែលអាចបត់បែនសំរួលបានចំពោះបុគ្គលិកបំរើការងារ។

៥ ការរំលោភផ្លូវភេទចាត់ទុកថាជាការល្មើសសិទ្ធិមនុស្សនិងជាការប្រតិបត្តិដោយមិនយុត្តិធម៌ដែលត្រូវតែលុបបំបាត់ចោលទាំងស្រុង។ ដោយមានការយល់ដូច្នេះត្រូវតែមាននយោបាយមួយដ៏តឹងរឹងសំរាប់ *"ការមិនអាចអត់ឱនបានឡើយ"* អំពីការរំលោពផ្លូវភេទនៅក្នុងកន្លែងធ្វើការ និងត្រូវរៀបចំឱ្យមានយន្តការដ៏មានប្រសិទ្ធិភាពដើម្បីបណ្ដឹងនៅរាល់ក្រុមហ៊ុន។ គោលការណ៍នយោបាយនេះត្រូវតែឱ្យមានការពង្រឹងតាមរយៈការធ្វើការបណ្តុះបណ្តាលដ៏សមរម្យដូចជាសិក្ខាសាលាដើម្បីជាការលើកកំពស់ការយល់ដឹងអំពីបញ្ហាជេនឌ័រក្នុងចំណោមបុគ្គលិកបំរើការងារក្រុមហ៊ុន។

៦ ត្រូវការឱ្យមានការស្វែងរកប្រភពនៃបញ្ហាការមិនយល់ដឹងអំពីបញ្ហាជេនឌ័របង្កប់នៅក្នុងសារព័ត៌មានទាំងសារព័ត៌មានបោះពុម្ពទាំងសារព័ត៌មានអ៊ីឡិចត្រូវណិច ដូចជាការយល់ដឹងដែលមានតាំងពីបុរាណមកនិងតំលៃខាងសង្គមនិងវប្បធម៌ពាក់ព័ន្ធទៅនិងស្ត្រីនិងក្មេងស្រីនិងដើម្បីអនុវត្តន៍ដូចតទៅះ

-សំរួលឱ្យមានការអនុវត្តន៍ច្បាប់ក្រុមសីលធម៌ស្តីអំពីការយល់ដឹងអំពីប្រធានបទជេនឌ័រដោយក្រុមហ៊ុនសារព័ត៌មាននិងក្រុមជំនាញការ។

-ផ្សព្វផ្សាយឱ្យមានវគ្គសិក្សាយល់ដឹងទាំងមុនចូលបំរើការងារនិងក្រោយពីបានចូលធ្វើការសំរាប់អ្នកសារព័ត៌ទាំងបុរសនិងស្ត្រី។

-អនុវត្តន៍ណែនាំស្របតាមគោលការណ៍ណែនាំ IFJ ក្នុងការធ្វើរបាយការណ៍ព័ត៌មានអំពើហិង្សាទៅលើស្ត្រីភេទ។

៧ សារព័ត៌មានទាំងស្ត្រីទាំងបុរសត្រូវតែទទួលការបណ្តុះបណ្តាលដូចជាការឃ្លាំមើលអំពីទស្សនះជេនឌ័រសារព័ត៌មាន។ អ្នកយកព័ត៌មាន អ្នកសរសេរអត្ថបទនិងពិធីករពិធីការិនីត្រូវតែបានទទួលស្គាល់វចនានុក្រមពាក្យឃ្លាខាងផ្នែកជេនឌ័រដែលជាប្រធានបទរសើបដើម្បីប្រឈមមុខនិងការប្រើប្រាស់ភាសាដ៏មិនសមរម្យគប្បីនិងមានលក្ខណៈបង្អាប់ខាងផ្លូវភេទក្នុងការប្រើប្រាស់ជាទូទៅ។

៨ សារព័ត៌មានមានការទទួលខុសត្រូវដើម្បីជំរាបនិងអប់រំសាធារណះស្របទៅតាមសន្ធិសញ្ញាអន្តរជាតិដែលសមភាពខាងជេនឌ័រចាត់ទុកជាមូលដ្ឋានសិទ្ធិមនុស្សនិងដើម្បីះ

-ឱ្យមានការផ្តោតអារមណ៍ទៅលើប្រធានបទពិតក្នុងជិវិតនិងការបង្កឧបសគ្គដែលធ្វើឱ្យមិនអាចប្រើប្រាស់សិទ្ធិមនុស្សដែលស្ត្រីនិងក្មេងស្រីនិងសហគមន៍ដែលបាត់បង់សិទ្ធិកំពុងតែប្រឈមមុខ។

-បង្ហាញដើម្បីឱ្យមានការយល់ដឹងថាតើស្ត្រីភេទមានចំណែកយ៉ាងសំខាន់យ៉ាងដូចម្តេចនៅកន្លែងធ្វើការងារនិងការផ្លាស់ប្តូរតួនាទីស្ត្រីនិងក្នុងធ្វើសំរេចចិត្តនិងជីវិតសាធារណះទូទៅ។

-របាយការណ៍អំពីផលអាក្រក់បណ្តាលមកពីច្បាប់ដែលមានការរើសអើង នយោបាយនិងគំនិតចាស់បុរាណនិងទស្សនះសង្គមនិងវប្បធម៌ ទំនៀមទំលាប់ ប្រពៃណីនិងការប្រតិបត្តិ។

## សមាគមអ្នកជំនាញវិជ្ជាជីវះនិងសហជីព

៩ សហជីពត្រូវតែធ្វើជំហានដ៏សកម្មមួយដើម្បីបង្កើនឱ្យមានតំណាងស្ត្រីរបស់សហជីព។ ប្រព័ន្ធកំណត់ចំនួនឬអត្រាតំណាងដោយផ្អែកទៅលើសារព័ត៌មាននីមួយ ៗ នឹងអាចផ្តល់តំណាងដ៏ពិតប្រាកដដល់ស្ត្រីភេទនៅក្នុងសហជីពនិងការចូលរួមដ៏ពិតប្រាកដ។ ផ្ទុយទៅវិញនេះនឹងអាចជំរុញឱ្យសហជីពនោះរីកចំរើ

ននិងរឹងមាំដោយមានការផ្តល់ការយល់ដឹងដោយការទាក់ទាញស្ត្រីជាសមាជិកនិងធ្វើឱ្យមានការបង្កើន សមត្ថភាពស្ត្រីនៅក្នុងសារព័ត៌មាន។

១០ សហជីពគួរជំរុញពិសោធន៍កម្មច្បាប់ផ្ទៃក្នុងនិងស្ថានៈធ្វើបែបនេះដើម្បីឱ្យរចនាសម្ព័ន្ធនោះ កាន់តែ "មានបរិយាកាសជាមិត្តនិងស្ត្រី" និងប្តេជ្ញាដើម្បីកសាងឱ្យមានសមភាពខាងជេនឌ័រនៅគ្រប់ ការិយាល័យក្នុងសហជីព។ នេះត្រូវតែឱ្យមានការរក្សាឬបង្កើនអាសនៈសំរាប់ស្ត្រីភេទនៅថ្នាក់ប្រតិបត្តិនិង ក្រុមអ្នកធ្វើការសំរេច។ ប្រព័ន្ធការកំណត់ចំនួនសំរាប់ការមានចំណែកពីស្ត្រីភេទក្នុងការប្រជុំក្រុមអ្នក គ្រប់គ្រង គណៈកម្មការ ក្រុមអ្នកចរចា ការបណ្តុះបណ្តាលនិងការសិក្សាអប់រំ។ ជាទីបញ្ចប់គឺនឹងអាច លើកកំពស់ការយល់ដឹងអំពីសមភាពជេនឌ័រនិងប្រធានបទពាក់ព័ន្ធនិងស្ត្រីភេទក្នុងចំណោមបុរសនិង ស្ត្រីដែលជាសមាជិក ការអភិវឌ្ឍន៍ឱ្យមានឯកភាពការបង្កើនធ្វើឱ្យស្ត្រីមានអំណាចនិងការកែប្រែទស្សនៈ ជាប្រពៃណីនិងហួសសម័យ។

១១ គ្រប់សហជីពគួរធ្វើការអនុវត្តន៍សមភាពជេនឌ័រសហជីពនិងនយោបាយគំរូ ការរំលោភផ្លូវភេទ ដោយផ្អែកទៅលើគោលការណ៍នយោបាយដែលមានហើយស្រាប់និងដែលកំពុងតែមានការអនុវត្តន៍នៅ ក្នុងភូមិភាគជាឧទាហរណ៍ជម្មនុញ្ញ SAMSN ស្តីអំពីសមភាពជេនឌ័រសំរាប់សារព័ត៌មាននិងអ្នកសារ ព័ត៌មាននៅភូមិអាស៊ីខាងត្បូងដែលអាចបញ្ចូលនិងឆ្នៃសំរាប់អង្គការសារព័ត៌មាន។

១២ សហជីពត្រូវតែកសាងបញ្ជីត្រួតពិនិត្យមួយសំរាប់ការប្រតិបត្តិរបស់សហជីពទៅលើសមភាពជេន ឌ័រក្នុងសកម្មភាពនៅកន្លែងធ្វើការ ការប្រតិបត្តិនិងនិយោជកនិងនិងរដ្ឋាភិបាល។ ទាំងនេះគួរបញ្ចូល អត្ថបទប្រឆាំងការរំលោពផ្លូវភេទដែលការកិច្ចព្រមព្រៀងការចរចាជារួមមួយនិងការជួបសន្ទនានិងរដ្ឋា ភិបាលដើម្បីកំណែទម្រង់ច្បាប់ស្តីអំពីបញ្ហាការរំលោភផ្លូវភេទ។ យុទ្ធនាការដែលមានគោលដៅទៅលើ ការធ្វើការពិនិត្យឡើងវិញប្រាក់ខែជាមួយនិងនិយោជកនិងលើកកំពស់ការប្រតិបត្តិល្អក្នុងកិច្ចព្រម ព្រៀងបង់ប្រាក់ខែការកាត់បន្ថយគំលាតខាងជេនឌ័រ ។ល។

**រដ្ឋាភិបាលសារព័ត៌មាននិងសង្គមស៊ីវិល**

១៣ ការបណ្តុះបណ្តាលសមភាពជេនឌ័រនោះជាការត្រូវការទាំងពីរនិងត្រូវការដោយបុរសនិងស្ត្រីដែលបំរើ ការងារនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ យុទ្ធសាស្ត្រគោលគឺវាត្រូវការឱ្យមានការលើកកំពស់កែលំអ បរិយាកាសការងារសំរាប់ស្ត្រីនិងបុរសដែលនឹងអាចជួយឱ្យបុគ្គលមានការយល់ដឹងកាន់តែល្អទៅលើ ប្រធានបទនេះនិងធ្វើការដើម្បីប្រឆាំងការសំលត់ការរំលោភនិងការរើសអើងក្នុងកន្លែងធ្វើការ។ ប៉ុន្តែវា នៅត្រូវការការយល់ដឹងយ៉ាងច្រើនទៀតទៅលើប្រធានបទសមភាពជេនឌ័រនិងសិទ្ធិរបស់ប្រជាជនទៅលើ បរិយាកាសការងារដែលពោរពេញទៅដោយគតិយុតិធម៍។ នេះគួរតែមានការផ្តោតអារមណ៍ទៅលើការ ជជែកគ្នាអំពីប្រាក់ខែ លក្ខ័ណការងារនិងស្ថានភាពការងារ។

Read the full report [here]